ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៨២
ចុះថ្ងៃទី ១៣-០១-២០១៧
សាលដីកា
លេខ ៣៧ ក្រ៣ -ល-
ចុះថ្ងៃទី ២៤-០៥-២០១៧

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៤ ។

បានបើកសវនាការជាសាធារណៈ នាសាលសវនាការនៃសាលាឧទ្ធរណ៍ នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០១៧ ដោយមានសមាសភាពដូចខាងក្រោម៖

## សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

## ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍សំណុំរឿងព្រហ្មទណ្ឌលេខ៨២ ចុះថ្ងៃទី១៣-០១-២០១៧ ដែលមាន៖

- ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ រាម ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ ចុងភៅហាងទឹកខ្ទែងកំណើតភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ទីលំនៅប[redacted]ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ[redacted]) នៅរស់ ជាទីតិជនទោសពីមុនគ្មាន ។ (ដីកាឃុំខ្លួនលេខ ៣៩២៥ ជឃជ ចុះថ្ងៃទី២៩.០៦.២០១៦ ម១)

មានលោក [redacted] ជាគុយ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

<u>ជាប់ចោទពីបទ:</u> រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចហាងយីហោ[redacted]រតនា ស្ថិតនៅបុរីកម្មករ ភូមិជើងឯក សង្កាត់ជើងឯក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាមឿន ភេទស្រី អាយុ ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ ហាងទីលំនៅបច្ចុប្បន្ន ភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ។





Scanned by CamScanner

-ជនរងគ្រោះឈ្មោះ[redacted] សុខគា ភេទស្រី អាយុ ១៣ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ មានទីលំនៅបច្ចុប្បន្ន [redacted] ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ។

បណ្តឹងឧទ្ធរណ៍លេខ ៩៣០ ចុះថ្ងៃទី ១៥-១២-២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] រតនា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥២៣ ក្រ៤ "ប" ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច។

## ៦រឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោងប្រហែលជា១៩ និង៤០នាទី ឈ្មោះ [redacted] រតនា ហៅ រាម បានទូរស័ព្ទទៅហៅឈ្មោះ [redacted]សុខគា ភេទស្រី អាយុ ១៣ឆ្នាំ ណាត់ជួបគ្នានៅវត្តជើងឯក ស្ថិតនៅក្នុងសង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ មួយខ្ទុះក្រោយមកឈ្មោះ [redacted] សុខគា បានតេទូរស័ព្ទឱ្យឈ្មោះ [redacted]រតនា ហៅ រាម ទៅយកនៅវត្តជើងឯក ហើយឈ្មោះ [redacted] រតនា ហៅ រាម បានដឹកឈ្មោះ[redacted] សុខគា ទៅកន្លែងធ្វើការនៅហាងយីហោ ពៅ រតនា ស្ថិតនៅភូមិបុរីកម្មករ សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ។ លុះម៉ោង ២៤ និង១០នាទី ឈ្មោះ[redacted] រតនា ហៅ រាម បានបបួលឈ្មោះ[redacted]សុខគា ឡើងដេកលើគ្រែ ដោយឈ្មោះ [redacted]តនា ហៅ រាម ស្លៀកក្រម៉ា អត់ពាក់អាវ ចំណែកឈ្មោះ[redacted] សុខគា ស្លៀកខោជើងវែង ពណ៌ត្រួយចេក មិនបានស្លៀកខោក្នុងនោះទេ ពាក់អាវដៃវែងពណ៌ខ្មៅ បន្ទាប់មកឈ្មោះ [redacted] រតនា ហៅ រាម បានអោបថើប យកដៃប្រឡេះឡេងអាវ និងសម្រាតខោអាវរបស់ឈ្មោះ [redacted] សុខគា ចេញ និងបានធ្វើសកម្មភាពរួមភេទជាមួយឈ្មោះ [redacted] សុខគា រហូតបានសម្រេចមួយដង។ លុះដល់ម៉ោងមួយរំលងអាធ្រាត្រឈ្មោះ[redacted] រតនា ហៅ រាម ក៏បានធ្វើសកម្មភាពរួមភេទជាមួយឈ្មោះ[redacted] សុខគា បានសម្រេចមួយដងទៀត។ លុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង ១៧ និង០០នាទី ក៏មានសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ជើងឯក ចុះធ្វើការឃាត់ខ្លួនឈ្មោះ[redacted]តនា ហៅ រាម នៅនឹងកន្លែងតែម្តង។

-បានឃើញ ចម្លើយរបស់ជនរងគ្រោះឈ្មោះ[redacted] សុខគា បានឆ្លើយនៅថា ខ្លួនពិតជាមានទំនាក់ទំនងស្រលាញ់គ្នាជាមួយឈ្មោះ [redacted]រតនា ហៅ រាម រយៈពេលមួយឆ្នាំជាងមកហើយ។ ខ្លួននឹងឈ្មោះ[redacted] រតនា ហៅ រាម ទើបបានរួមភេទជាមួយគ្នានៅថ្ងៃកើតហេតុបានចំនួនពីរដងប៉ុណ្ណោះ។ ខ្លួនចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនច្បាស់ គឺកើតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៣ និងមានសំបុត្រកំណើតបញ្ជាក់កំណើតលេខ ៣១៧៥ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៥ ពិតប្រាកដមែន។ ហើយនៅយប់ថ្ងៃនោះគាត់បានមកយកខ្លួននៅក្បែរវត្តនឹងបានឱ្យខ្លួនចាំនៅមុខហាង លុះពេលបិទហាងពួកយើងក៏ចូលគេងជាមួយគ្នា ហើយគាត់បានសុំរួមភេទជាមួយខ្លួន ខ្លួនក៏បានយល់ព្រមអត់មានប្រកែកនោះទេ គាត់ជាអ្នកដោះខោអាវខ្លួន ហើយក៏បានទាញកន្សែងគ្របខ្លួន។ ខ្លួនពុំដែលប្រាប់អាយុរបស់ខ្លួនទៅគាត់នោះទេ។

-បានឃើញ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សាមឿន បានឆ្លើយនៅថា ខ្លួនត្រូវជាម្តាយរបស់ជនរងគ្រោះនៅថ្ងៃកើតហេតុបន្ទាប់ពីកូនរបស់ខ្លួននិយាយប្រាប់ពីដំណើររឿងដែលឈ្មោះ [redacted]តនា



Scanned by CamScanner

ហៅ រាម បានប្រព្រឹត្តមកលើកូនរបស់ខ្លួន ខ្លួនក៏បាននាំកូនទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលខណ្ឌ ជើងឯក។ ពេលនោះឈ្មោះ [redacted] រតនា និងឪពុកម្តាយរបស់ឈ្មោះ [redacted] រតនា បាននិយាយអង្វរកខ្លួន កុំឱ្យមានការប្តឹងផ្តល់អ្វី ពួកគាត់ធានានឹងរៀបចំកូនថៅការទៅតាមប្រពៃណី តែឪពុកម្តាយរបស់ឈ្មោះ [redacted] រតនា មិនបានធ្វើលិខិតស្នាមជាលាយលក្ខណ៍អក្សរនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ដើម្បីឱ្យមានទំនុកចិត្តឡើយ រហូតមកដល់សព្វថ្ងៃ។ ខ្លួនយល់ព្រមដកពាក្យបណ្តឹងវិញ ដោយសារខាងក្រុមគ្រួសារជនជាប់ចោទបានសន្យាឱ្យប្រាក់ និងរៀបការកូនតាមប្រពៃណី តែចាប់ពីថ្ងៃនោះមកជនជាប់ចោទមិនបានបំពេញ ឬធ្វើតាមការសន្យាឡើយ។ នៅក្នុងរឿងនៅតែប្តឹងទាមទារសំណងជម្ងឺចិត្តពីជនជាប់ចោទចំនួន ៣០០០ $ (បីពាន់ដុល្លារអាមេរិក) ដើម្បីរៀបចំការកូនទៅតាមប្រពៃណីទើបខ្លួនយល់ព្រម ដកពាក្យបណ្តឹងវិញ បើមិនដូច្នេះទេ ខ្លួនសុំឱ្យតុលាការចាត់ការតាមច្បាប់។

*បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៥២៣ ក្រ៤ "ច" ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចខាងក្រោម៖*

៤.១-ផ្តន្ទាទោស

-ឈ្មោះ [redacted] រតនា ហៅ រាម ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៥ឆ្នាំ (ប្រាំឆ្នាំ)

ពីបទ៖ រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចហាងយីហោ [redacted] រតនា ស្ថិតនៅបុរីកម្មករ ភូមិជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃ២៥ ខែមិថុនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។

៤.២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ រាម ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ សងសំណងជម្ងឺចិត្តទៅឈ្មោះ [redacted] សាមឿន ជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨.០០០.០០០៛ (ប្រាំបីលានរៀល)។

-ការទាមទារលើសពីនេះច្រានចោល។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌ ចុះថ្ងៃទី ០២-០២-២០១៧ របស់សាលាឧទ្ធរណ៍ ។

បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ០៨-០៤-២០១៧ របស់មហាអយ្យការអមសាលាឧទ្ធរណ៍។

បានឃើញ ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះទី២លេខ ១៩ ដក២០១៧ ចុះថ្ងៃទី ០២-០៣-២០១៧។



Scanned by CamScanner

## នាពេលសវនាការ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាមឿន (អវត្តមាន)

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] រតនា បានឆ្លើយថា ខ្លួនព្រមទទួលយកលោក [redacted] ជាគុយ ជាមេធាវីការពារសិទ្ធិឱ្យខ្លួន។ ខ្លួនសូមឱ្យក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសឱ្យខ្លួនផងដោយហេតុថា ពួកយើងស្រលាញ់គ្នា។ គេមិនដែលប្រាប់ពីអាយុគេដល់ខ្លួនទេ។ ពួកយើងស្គាល់គ្នាជាមួយឆ្នាំហើយ ខ្លួនមិនដឹងពីអាយុគេទេ គេធំហើយគេធ្វើការរោងចក្រ។ កន្លែងរួមភេទ គឺនៅកន្លែងដែលខ្លួនគេងរាល់ថ្ងៃ ពួកយើងរួមភេទបាន២ដង។ ខ្លួនទើបតែមកនៅផ្ទះនេះបានមួយឆ្នាំ។ ម្តាយគេជាអ្នកប្តឹង ខ្លួនមិនដឹងថាយ៉ាងម៉េចបានជាគាត់ប្តឹងទេ។ ខ្លួនមានលទ្ធភាពសងសំណងតែ២លានទេ។ ពេលកើតហេតុគ្មានការភ្ញាក់ផ្អើលទេ។ ខ្លួនស្រលាញ់គេរហូត ខ្លួនមានបំណងយកគេធ្វើជាប្រពន្ធ ខ្លួនមិនមានបំណងរួមភេទជាមួយនាងហើយបោះបង់ចោលទេ។ សំណូមពរឱ្យក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសដល់ខ្លួនផង។

-តំណាងមហាអយ្យការសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឃើញថា ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់យោងមាត្រា៣៧៥ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ជនជាប់ចោទប្តឹងឧទ្ធរណ៍សុំឱ្យសាលាឧទ្ធរណ៍សម្រេចជាថ្មី ជនជាប់ចោទបដិសេធថាមិនដឹងពីអាយុរបស់ជនរងគ្រោះ ប៉ុន្តែតាមចម្លើយរបស់ឪពុកម្តាយគឺជនរងគ្រោះមានអាយុ១៣ឆ្នាំ។ ការរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ទោះបីជាមានការព្រមព្រៀងគ្នាក៏ត្រូវមានទោសដែរ។ សំណូមពរ ឱ្យក្រុមប្រឹក្សាសម្រេចតម្កល់សាលាក្រមរបស់សាលាដំបូងទុកជាបានការដដែល។

-លោក [redacted] ជាគុយ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទសន្និដ្ឋានថា ក្រោយពីពិភាក្សាដេញដោលឃើញថាកូនក្តីខ្លួន និងជនរងគ្រោះគឺស្រលាញ់គ្នា ហើយការរួមភេទគឺដោយការព្រមព្រៀង កូនក្តីខ្លួនមិនបានបង្ខិតបង្ខំនោះទេ។ ជាងនេះទៅទៀត កូនក្តីខ្លួនមិនបានដឹងពីអាយុរបស់ជនរងគ្រោះទេ តែកូនក្តីខ្លួនគិតថាជនរងគ្រោះមានអាយុច្រើនដោយហេតុថាជនរងគ្រោះធ្វើការរោងចក្រ។ សូមឱ្យក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនតាមបញ្ញត្តិមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ។

*ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ*

*ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ*

*ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ*

*ក្រោយពីបានពិចារណាលើគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ*

*ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ*



Scanned by CamScanner

# <u>សាលាឧទ្ធរណ៍</u>

## យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍លេខ ៩៣០ ចុះថ្ងៃទី ១៥-១២-២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] រតនា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥២៣ ក្រ៤ "ឋ" ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច បណ្តឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះយកមកជំនុំជម្រះបាន យោងតាមមាត្រា ៣៧៦ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted] រតនា បានឆ្លើយសារភាពថាខ្លួនពិតជាបានរួមភេទជាមួយជនរងគ្រោះប្រាកដមែន ប៉ុន្តែមិនបានដឹងថាជនរងគ្រោះជាអនីតិជនអាយុក្រោម១៥ឆ្នាំទេ។ ក្រុមប្រឹក្សាយល់ឃើញថាការអះអាងនេះមិនអាចឲ្យក្រុមប្រឹក្សាជឿបានទេ ដោយហេតុថាផ្អែកតាមរូបរាងរបស់ជនជនរងគ្រោះឃើញថាជនរងគ្រោះមានវ័យក្មេង និងមាឌតូច ហេតុនេះមិនអាចជនជាប់ចោទមើលមិនដឹងពីអាយុរបស់ជនរងគ្រោះ ថាជាអនីតិជននោះទេ ។

៣-ក្រុមប្រឹក្សាយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted]រតនា ពិតបានរួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted]សុខគា ហើយជនរងគ្រោះជាអនីតិជនមានអាយុក្រោម១៥ឆ្នាំផ្អែកតាមសំបុត្របញ្ជាក់កំណើត (ឯកសារលេខ ១)។ អំពើរបស់ជនជាប់ចោទជាបទ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ដែលត្រូវបានបញ្ញត្តិឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។

៤-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងមហាអយ្យការដែលសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឃើញថាធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់យោងមាត្រា ៣៧៥ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ជនជាប់ចោទប្តឹងឧទ្ធរណ៍សុំឲ្យសាលាឧទ្ធរណ៍សម្រេចជាថ្មី ជនជាប់ចោទបដិសេធថាមិនដឹងពីអាយុរបស់ជនរងគ្រោះ ប៉ុន្តែតាមចម្លើយរបស់ឪពុកម្តាយគឺជនរងគ្រោះមានអាយុ១៣ឆ្នាំ។ ការរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ទោះបីជាមានការព្រមព្រៀងគ្នាក៏ត្រូវមានទោសដែរ។ សំណូមពរឲ្យក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល។ គប្បីក្រុមប្រឹក្សាពិចារណា។

៥-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទដែលសន្និដ្ឋានថា ក្រោយពីពិភាក្សាដេញដោល ឃើញថាកូនក្តីខ្លួន និងជនរងគ្រោះគឺស្រលាញ់គ្នា ហើយការរួមភេទគឺដោយការព្រមព្រៀង កូនក្តីខ្លួនមិនបានបង្ខិតបង្ខំនោះទេ។ ជាងនេះទៅទៀត កូនក្តីខ្លួនមិនបានដឹងពីអាយុរបស់ជនរងគ្រោះទេ តែកូនក្តីខ្លួនគិតថាជនរងគ្រោះមានអាយុច្រើនដោយហេតុថាជនរងគ្រោះធ្វើការរោងចក្រ។ សូមឲ្យក្រុមប្រឹក្សាសម្រេចបន្ធូរ



Scanned by CamScanner

បន្ថយទោសដល់កូនក្តីខ្លួនតាមបញ្ញត្តិមាត្រា៩៣នៃក្រមព្រហ្មទណ្ឌ។ ក្រុមប្រឹក្សាយល់ឃើញថា តាមកាលៈទេសៈការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទពុំមានស្ថានភាពណាដើម្បីយកមកជាមូលហេតុនៃការបន្ធូរបន្ថយទោសដល់ជនជាប់ចោទឡើយ។ ម៉្យាងវិញទៀត ដើម្បីពង្រឹងនូវការអនុវត្តច្បាប់ឱ្យបានតឹងរឹង និងបង្ការបទ ល្មើសនេះកុំឱ្យរីករាលដាលក្នុងសង្គម ហេតុនេះ ពុំគប្បីមានការបន្ធូរបន្ថយទោសឡើយ ។

៦-ក្រុមប្រឹក្សាយល់ឃើញថា សាលក្រមព្រហ្មទណ្ឌលេខ ៥២៣ ក្រ៤ "ឋ" ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានលើកយកសំអាងហេតុ និង សេចក្តីសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់រួចហើយ គប្បីក្រុមប្រឹក្សាតម្កល់ទុកសេចក្តីសម្រេចនេះជាបានការជាធរមាន ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៩៣០ ចុះថ្ងៃទី ១៥-១២-២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥២៣ ក្រ៤ "ឋ" ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការជាធរមាន ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] តាមនីតិវិធី។

៤-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

បើកប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា

ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
*រាជធានីភ្នំពេញ* ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧
ក្រឡាបញ្ជី

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ